# ការសម្ភាសរបស់លោកយាយ ហៀន ហ៊ន

ក៖ អ្នកសម្ភាសន៍ រត្ន ស្រីភាព ខ៖ អ្នកដែរបានសម្ភាសន៍ ហៀនហ៊ន

**ការសម្ភាសន៍ជីវប្រវត្តការសង្ខេបរបស់ម៉ាក់យាយឈ្មោះ ហៀន ហ៊ន**

គាត់ជាមនុស្សម្នាក់ដែលពិបាកតាំងពីតូចរហូតមកដល់ឥឡូវហើយគាត់មានការលំបាកតែគាត់ជាមនុស្សដែលតស៊ូខិតខំប្រឹងប្រែងគាត់ធ្លាប់ធ្វើការសំណងអស់រយះពេល៤ឆ្នាំហើយគាត់ក៏ធ្លាប់ធ្វើការរោងចក្រដែរ។

ក៖ ចឹងជាដំបូងនាងខ្ញុំសំជំរាប់សួរម៉ាកយាយចាំហើយនាងខ្ញុំឈ្មោះរត្ន ស្រីភាពសុំអនុញ្ញាតសម្ភាសជីវប្រវត្តិរបស់ម៉ាកយាយនៅពេលដែរខ្ញុំធ្វើការសម្ភាសនឹងគឺបានធ្វើឡើងដោយសាលារៀនមួយគេបានហៅថាសាលាB y u នៅអាមេរិចណាលោកយាយដើម្បីថែរក្សាជីវប្រវត្តិរបស់ម៉ាកយាយនឹងបានថែរក្សាជីវប្រវត្តិដូនតារបស់ម៉ាកយាយដើម្បីចង់ក្រងទុកអោយកូនចៅជំនាន់ក្រោយអោយគេនឹងបានដឹងថាតើអ្នកជំនាន់មុននឹងគេបានរស់នៅដោតរបៀនណាហើយគេនឹងបានគស្គាល់ពួកគេពីមួយជំនាន់ទៅមួយជំនាន់ដោយរបៀនណាខ្លះក្នុងជីវិតរបស់ពួកគេហើយខ្ញុំសូមបញ្ជាក់ថាពេលដែរខ្ញុំសុំធ្វើការសម្ភាសនឹងគឺធ្វើនៅថ្ងៃទី១០ខែ០៥ នៅឆ្នាំ២០១៨។

ក៖ តើម៉ាកយាយមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំឈ្មោះហៀន ហ៊ន។

ក៖ ចឹងម៉ាកយាយមានឈ្មោះហៅខាងក្រៅទេ?

ខ៖ ហ៊ន ឈ្មោះហ៊ននឹងទទេ។

ក៖ ម៉ាកមានហ៊នខាងក្រៅនឹងហើយម៉ាកយាយនឹងអត់មានរហស្សនាមខាងក្រៅទេម៉ាកយាយ?

ខ៖ គេនឹងបានហៅតែយាយហ៊នៗ។

ក៖ សព្វថ្ងៃនឹងម៉ាកយាយមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំនឹងសែសិបប្រាំបួនឆ្នាំ។

ក៖ សែសិបប្រាំបួនឆ្នាំនៃម៉ាកយាយ ម៉ាកយាយអាចប្រាប់ខ្ញុំបានទេថាម៉ាកយាយចាំថ្ងៃខែឆ្នាំកំណើតកើតនៅថ្ងៃណាខែណាទេ?

ខ៖ ខ្ញុំទល់តែយកបញ្ជីរជាតិនឹងមក។

ក៖ ចា៎ ចឹងខ្ញុំសូមអនុញ្ញាតសុំយកបញ្ជីរជាតិនឹងមកមើល ចាំចឹងម៉ាកយាយកើតនៅថ្ងៃទី១៤ ខែ ០៤ នៅឆ្នាំ១៩៧០ហើយខ្ញុំសូមអាបនៅក្នុងបញ្ជីរកំណើតផ្ទាល់ទាំងអស់នឹងតែម្តងនឹងណា?

ខ៖ ចា៎ៗ

ក៖ ម៉ាកយាយនៅភូមិ ត្រាំង ឃុំត្រដួចស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។

ខ៖ ភូមិតាពរ។

ក៖ អត់ទេនេះគេបានដាក់?

ខ៖ អរ គរដាល់ខុសហើយចឹង។

ក៖ ហើយនៅក្នុងស្វាយរៀងនៅប្រទេសកម្ពុជាយើងនឹងណាម៉ាកយាយ?

ខ៖ ចា៎!

ក៖ ហើយដូចជាខ្ញុំសុំអានពីងនឹងសិនចាំដល់លោកឪពុកចាំខ្ញុំបញ្ជាក់ម្តងទៀត?

ខ៖ ចា!

ក៖ ចឹងតើម៉ាកយាយអាចប្រាប់ខ្ញុំបានទេថាមាកយាយមានឆ្នាំខ្មែរហៅថាឆ្នាំកាតិតជូត ឆ្លូវ ខាល ថោះណាតើម៉ាកយាយនឹងមានឆ្នាំអ្វីដែរ?

ខ៖ ខ្ញុំនឹងឆ្នាំ ចរ។

ក៖ ឆ្នាំ ចរ ម៉ាកយាយជាអ្នកស្រុកកំណើតនៅទីក្រុងភ្នំពេញ?

ខ៖ ស្រុកកំណើតខ្ញុំនៅស្រុកស្វាយរៀងម្តងគ្រូ។

ក៖ ចាំ! ដូចខ្ញុំបានអានមិញចឹងម៉ាកយាយ?
ខ៖ ចាំ!
ក៖ ចាំ រស់នៅខេត្តស្វាយរៀងនឹង
ម៉ាកយាយបានផ្លាក់មករស់នៅទីក្រុងភ្នំពេញនឹងអស់រយះពេលនឹងប៉ុន្មានឆ្នាំហើយ
ខ៖ មើលខ្ញុំចូលមករស់នៅនឹងចូលសាមសិបឆ្នាំហើយ អរ
មើលចូលម្ភៃប្រាំបីឆ្នាំហើយ។
ក៖ ចាំ!
ចឹងមានន័យថាម៉ាកយាយមករស់នៅនឹងជំនាន់ប៉ែតសិបជាងចាំចឹងម៉ាកយាយមករស់នៅទីក្រងភ្នំពេញនឹងពីដំបូងមករស់នៅនឹងតែម្ដងឬមួយបានរស់នៅកន្លែងផ្សេង?
ខ៖
ខ្ញុំមករស់នៅដំបូងនឹងនៅច្បារអំពៅចាំដល់ពេលភ្លើឆេះនៅតាមមួយជួរមាត់ទន្លេឆេះផ្ទះខ្ញុំអស់ទៅខ្ញុំនឹងបាននៅសែនសុខ។
ក៖ ចាំ!
ខ៖ ខ្ញុំនឹងបានប្ដូរទីលំនៅនឹងទៅនៅនឹង។
ក៖ ចាំ!
ខ៖ ដូចថាយើងនឹងមិនបានព្រមទៅគេនឹងបានលួចដុត។
ក៖ លួចដុតនៅខាងច្បារអំពៅនឹងទៅ?
ខ៖ ចាំៗ មាត់ទន្លេច្បារអំពៅនឹងជិតគល់ស្ពាននឹង។
ក៖ ចាំ!
ខ៖
គេនឹងបានដុតបីដងហើយយើងនឹងមិនបានព្រមទៅគេដុតឆេះអស់ចឹងទៅដល់ចឹងទៅខ្ញុំនឹងក៏បានព្រមទៅ។
ក៖ ព្រមចេញមកវិញមក?
ខ៖ ចាំ
ខ្ញុំនឹងបានចេញទៅហើយដល់ទៅគេនឹងបានចែកដីឡូលម៉ារគ្រួសារនឹងមួយឡូល។
ក៖ មួយឡូលនឹងប៉ុន្មានដែរ?
ខ៖ មួយឡូលនឹងទទឹងប្រាំពីក្រោយនឹងបានដប់ប្រាំម៉ែត។
ក៖អរ  នឹងគេបានហៅមួយឡូល?
ខ៖ ចាំ! មួយឡូលៗនឹងណា
ហើយប្រាំត្រឹមជង្គួតនឹងហើយគ្មានទឹកអីនឹងវេនាហើយនឹងពិបាកអើយពិបាក។
ក៖ ចាំ!
ខ៖
ដល់ពេលហើយចឹងទៅរៀបបីខែប្ដីខ្ញុំនឹងគាត់បានឈឺរគាត់ឈឺរហើយទៅកាត់ពងចោលអីចឹង។
ក៖ ចាំ!
ខ៖ ការនឹងជំនាន់នឹងខ្ញុំនឹងបានលក់បានតែពីរយហា។
ក៖ អូរអ្នកមីងនឹងបានលក់ដីនៅបឹងកន្លែងគឺឡូប្រាំមួយនឹង?
ខ៖ ចាំ នៅសែនសុខនឹង។
ក៖ នៅសែនសុខបានតែពីរយហា?
ខ៖
ការនឹងបានតែពីរយហាយើងនឹងចូលនៅដំបូងបានតែពីបីខែនឹងគាត់នឹងគាត់បានចាប់ផ្ដើមគាត់នឹងបានឈឺគាត់នឹងបានហើមពងចឹងអីទៅខ្ញុំនឹងបានមើលអស់គាត់នឹងអត់ជាចង់ទៅខ្ញុំនឹងបានលក់ដី។
ក៖ ការនឹងគាត់នឹងបានឈឺរនឹងពោះវៀនចូលមែន?
ខ៖ អត់ទេគាត់នឹងបានកាត់ចោលម្ដងកាត់មេនឹងចោល។
ក៖ ចឹងមានន័យថា?
ខ៖
ការនឹងមិនបានដឹងថាគាត់នឹងបានកើតអីកាលនឹងដល់ពេលបានទៅពេទ្យនឹ

ងដំបៅនឹងវាបានរីតហើយដល់ចឹងទៅវានឹងបានស៊ីហើយពារឡនឹងថាបើទុកវានឹងឆ្លង។
ក៖ ចា៎!
ខ៖
ឆ្លងបង់ដើរអោយងាប់ស៊ីអស់នឹងយើងងាប់ពីព្រោះបើយើងនឹងកាត់អាមេចោលនឹងយើងរស់។
ក៖ ចា៎!
ខ៖
ទៅពារឡភពក្រុងហើយពារឡនឹងបានកាត់ចោលអស់រលីងយើងនឹងដូចជាស្រីធម្មតា។
ក៖ ចា៎!
ខ៖
កាលនឹងខ្ញុំនឹងបានមើលគាត់អស់ក៏មិនបានជាលក់ដីអស់ក៏គាត់នឹងនៅមិនបានជា។
ក៖ ហើយសព្វថ្ងៃនឹងគាត់នឹងបានធូរខ្លះទេ?
ខ៖ ប្ដីខ្ញុំនឹងគាត់បានស្លាប់ហើយ។
ក៖ អរ នេះជាស្វាយមីនឹងក្រោយ?
ខ៖ ចា៎ នឹងប្ដីខ្ញុំក្រោយ។
ក៖ អរ ដែរអ្នកមីងនឹងនិយាយនឹងគឺស្វាយមីមុន?
ខ៖ ចា៎ប្ដីខ្ញុំមុន។
ក៖
នឹងហើយចឹងអ្នកមីងនឹងបានរស់ផ្លាក់ប្ដូរមករស់នៅនឹងបានគាត់នឹងបានស្លាប់ហើយចឹងទៅបានម៉ាកយាយនឹងបានទទួលជីវិតនឹងស្វាយមីនឹងក្រោយ?
ខ៖ ចា៎ដល់ចឹងទៅខ្ញុំនឹងបានមេម៉ាយបានប្រាំពីឆ្នាំនឹងបានខ្ញុំនឹងបានមានប្ដី។
ក៖ ស្វាយមីមុននឹងបានកូនឹងប៉ុន្មានអ្នកមីង?
ខ៖ខ្ញុំនឹងបានកូនប្រាំ។
ក៖ កូននឹងប្រាំ?
ខ៖ ចា៎ ទើបនឹងបានរៀបមួយហើយនៅប្អូននាក់ទៀត។
ក៖ ហើយចុះមកយកគាត់នឹងបានកូនប៉ុន្មានហើយ?
ខ៖ ខ្ញុំនឹងអត់ទាន់មានផងនឹងអូន
អត់មានគាត់នឹងចាស់ហើយមិនគាត់នឹងមានទៀត។
ក៖  ចា៎
ដោយសារយើងនឹងបានយកគាត់នឹងមិនមែនតែដូចជាយើងនឹងបានយកគាត់នឹងបានទុកជាចំហរមួយនៅក្នុងគ្រួសារណា?
ខ៖ ចា៎!
ក៖ ចា៎ មានពេលខ្លះយើងនៅតែម្នាក់ឯងយើងនឹងមេម៉ាក៏មិនបានកើតដែរ?
ខ៖ មេម៉ាគេនឹងបានមើលងាយហើយខ្ញុំនឹងបានយកគាត់នឹងជាចំហរនឹងណា។
ក៖ ចា៎
ចូលថាគាត់នឹងមិនបានមានអីដែលបានផំដុំផ្ដលអោយយើងប៉ុន្តែគាត់ជាមេគ្រួសារនឹងម្នាក់ដែរនឹងណាចា៎?
ខ៖ ចា៎!
ក៖
ចឹងអ្នកមីងនឹងបានមករស់នៅក្នុងសង្កាត់នឹងគេបានហៅសង្កាត់អីគេដែរអ្នកមីង?
ខ៖ សង្កាត់បឹងស្រលាង។
ក៖ សង្កាត់នឹងបឹងស្រលាង ?
ខ៖ ខណ្ឌ័ឬស្សីកែវ រាជធានីភ្នំពេញ។
ក៖
ចឹងអើយសំរាប់អ្នកមីងផ្ទាល់គ្រួសាររបស់អ្នកមីងនឹងតើមានបងប្អូននឹងប៉ុន្មានដែរ?
ខ៖ ខ្ញុំបងប្អូនប្រាំពី។

កៈ ប្រាំពីនាក់ ប្រុសប៉ុន្មានហើយស្រីនឹងប៉ុន្មានអ្នកមីង?
ខៈ ស្រីបី ហើយនឹងប្រុសបួន។
កៈ ចាំ!
ខៈ
តែគេនឹងបានរស់នៅស្វាយរៀងនឹងទាំងអស់អត់តែខ្ញុំហើយនៅនឹងតែម្នាក់ឯង ពិបាកនឹងតែម្នាក់ឯង។
កៈ ចាំ ចឹងស្រីបី
ប្រុសបួននឹងអ្នកមីងនឹងអាចប្រាប់ខ្ញុំបានទេដូចជាអ្នកមីងនឹងជាកូនទីប៉ុន្មានដែរ?
ខៈ ខ្ញុំនឹងជាកូនទីពី។
កៈ ជាកូនទីពី?
ខៈ ចាំ !
កៈ
សំរាប់អ្នកមីងផ្ទាល់តើអ្នកមីងអនុញ្ញាតអោយខ្ញុំនឹងបានស្គាល់ឈ្មោះបងប្អូនទាំងប្រាំពីនាក់បងប្អូនអ្នកមីងនឹងបានទេតើគាត់នឹងមានឈ្មោះអីខ្លះ?
ខៈ ចាំ ស្គាល់បានតើ។
កៈ ចាំ!
ខៈ ឈ្មោះមើលបើបងឈ្មោះខាងផារអរ ហៀនហុត។
កៈ ហៀនហុត។
ខៈ ហើយមកបន្ទមកខ្ញុំនឹងហៀនហ៊ន។
ក ចាំហៀនហ៊ន?
ខៈ ចាំបន្ទអាប្អូនខ្ញុំនឹងអាមួយទៀតហៀន ហម
ហៀមហៀមស្អិតតែអាឪពុកនឹងជាអ្នកដែរបានដាក់អោយនឹងទាំងអស់។
កៈ ចាំ ហៀនហម ?
ខៈ ហៀនហម ហើយមួយទៀតនឹងហៀនហៀម។
កៈ ចាំហើយមួយទៀត?
ខៈ បន្ទមកទៀតនឹងហៀនហួន។
កៈ ចាំ!
ខៈ ហៀនហួន។
កៈ ចាំ ហើយក្រោយមកទៀត?
ខៈ ហៀន គម។
កៈ ហៀន គម?
ខៈ ចាំ !
កៈ អស់ហើយអ្នកមីង?
ខៈ នៅមួយទៀត។
កៈ ចាំ!
ខៈ ហៀនហឿង។
កៈ នៅហៀនហឿងនឹងមួយទៀត?
ខៈ ចាំ! ស្អិតតែប្រុសៗនឹងទាំងអស់នឹង។
កៈ ចាំចឹងបងប្អូនអ្នកមីងនឹងស្អិតតែត្រកូលហៀន?
ខៈ ចាំនឹងស្អិតតែឪពុកនឹងបាមដាក់អោយ។
កៈ ត្រកូលហៀន
ចឹងអើយសំរាប់អ្នកមីងផ្ទាល់តើអ្នកឹងអើយមានបានចាំអនុស្សាវរិយ៍ការនៅពីក្មេងជាមួយនឹងបងប្អូនរបស់អ្នកមីងដូចជាធ្លាប់បានធ្វើបានធ្វើការជាមួយនឹងបងប្អូន?
ខៈ ធ្លាប់ចាំតើគ្រួ។
កៈ ពិបាកអីខ្លះអ្នកមីង?
ខៈ
អើយអ្នកគ្រូអើយពិបាកណាស់ម៉ែឪនឹងក្រដើរស៊ីឈ្នួនសួនគេយកលយុនឹងមកចិញ្ចឹមឪពុកម្តាយ។
កៈ ចាំ!

ខ៖
ដើរស៊ីឈ្នួនគេនឹងផងចឹងទៅអោយរួចផុតខែអើយយើងនឹងបានសួននឹងដល់រួចទីផុតពីខែសួននឹងដើរធ្វើការសំណាង់គេនៅទីរួមខេត្តស្វាយរៀងនឹងតែម្តង។
ក៖ អ្នកមិងនឹងបានឆ្លងកាត់នឹងច្រើនណាស់?
ខ៖ ហើយការនឹងខ្ញុំនឹងបានធ្វើនឹងបានតែប៉ុន្មានពាន់ទេកាលនឹង?
ក៖ ការនឹងអ្នកមីងនឹងបានធ្វើនឹងបានប៉ុន្មានការនឹង?
ខ៖
ប៉ុន្មនាទេកាលនឹងបានតែពីពាន់នឹងការនឹងមិនបានរូចថ្លៃទេកាលនឹងបើមាសនឹងមួយជីនឹងបានតែដប់ពីម៉ឺនកាលនឹង។
ក៖ ចាំៗ
ខ៖ ដប់ពីម៉ឺនការនឹងម៉ារដប់មួយម៉ឺនការនឹង។
ក៖ ចាំ!
ខ៖ ដើរស៊ីឈ្នួនគេនឹងយកលយុនឹងមកអោយម្តាយឪ។
ក៖ ចាំ!
ខ៖
ហើយរៀបឡើងទៅធ្វើការចឹងខ្ញុំនឹងបានឡើងទៅរែកទឹកទៀតពេញពៀងអោយម៉ែពៀងនឹងកាលនឹងយើងនឹងបានយកយូងដៃ។
ក៖ ចាំ!
ខ៖ ការនឹងមិនបានទាន់មានអណ្តូរសួន។
ក៖ ការនឹងអត់ទាន់មានទេកាលនឹង?
ខ៖ហើយខ្ញុំនឹងបានរែកនឹងមួយគីឡូដី។
ក៖ ស្លាប់!
ខ៖
ធុមពីងចឹងរែកទឹកដាក់ចេពៀមហើយបានខ្ញុំនឹងបានជិះកង់ខ្លីតៗទៅធ្វើការ។
ក៖ ចាំ!
ខ៖
ដល់ម៉ោងប្រាំល្ងាងនឹងខ្ញុំបានចេញមកពីធ្វើការជិះកង់នឹងមកវិញទៀតហើយជួនការធ្វើការនឹងអស់កំម្លាំងសុំម៉ែដេកនៅនឹង។
ក៖ ចាំ!
ខ៖ ដេកជាមួយមីងដេកជាមួយនឹងបងប្អូននឹងពីការជុំគ្នានៅនឹង។
ក៖ ធ្វើការអីគេ?
ខ៖
សំណាង់ហើយខ្ញុំនឹងបាននៅរេងគ្រួចនៅនឹងហើយនឹងបានខូកសំណាង់នឹងអោយជាងចាំ។
ក៖ ចាំ ហើយបានតែប៉ុន្មានពានញទៀតក្នុងមួយថ្ងៃ?
ខ៖ បានប៉ុន្មានពាន់កាលនឹង។
ក៖ ប្រាំពីពាន់?
ខ៖ ប្រាំពីពាន់នឹងកាលនឹងបានតែប្រាំពាន់។
ក៖ ប្រាំពីពាន់?
ខ៖
ដល់ពេលបានរួចពីនឹងមកខ្ញុំនឹងបានធ្វើសំណាង់នឹងតាមផ្ទះគេនឹងហើយហើយម៉ែឪខ្ញុំនឹងបាននាំខ្ញុំនឹងមកនៅពេញហើយឪខ្ញុំនឹងបានជាអ្នកផាក់ស៊ីខ្លូ។
ក៖ អូអ្នកមីងនឹងបានធ្លាប់ផាក់ស៊ីខ្លូដែលកាលនឹង?
ខ៖
អត់ទេឪពុកខ្ញុំផាក់ស៊ីខ្លូចឹងទៅហើយម៉ែខ្ញុំនឹងទិញឪឡឹកទិញចឹងទៅផ្លែឈើចឹងមកអោយខ្ញុំនឹងដើរទូលក់។
ក៖ ចាំៗ
ខ៖ ចាំ ទូរដើរលក់នឹងចេញផ្សារអូឬស្សីនឹងផ្សារស៊ីលីមអីនឹងណា។
ក៖ ចាំៗ
ខ៖ នៅចឹងនឹងបានបីឆ្នាំ។
ក៖ អូចាំ?

ខះ បីឆ្នាំខ្ញុំនៅតូចៗពេននឹងទេនៀក។
កះ ចាំៗ
ខះ ម៉ែខ្ញុំនឹងគាត់បានបង់ហាត់អោយកូនឹងចេះរកស៊ីស្វាយ ម្នាស់
លក់អីចឹងណាកាលនឹងគាត់នឹងបានទិញអោយមកលក់កាលនឹងខ្ញុំនឹងបានប្រាំកាសចឹងទៅហើយនឹងបានបីកាសចឹងកាលនឹងម៉ារក្រដាក់ប្រាំរយហើយកាលនឹងបានមួយរយនឹងអត់បានដឹងទេហើយខ្ញុំនឹងចង់ភ្លេច។
កះ ចាំ!
ខះ មួយរយដឹងពីរយមិនដឹង។
កះ ចាំ!
ខះ
ជំនាន់នឹងកំពុងដើរលក់ដាក់អើយដាក់ការនឹងលក់ដាក់ហើយខ្ញុំនឹងនៅអំពៀលអើយមីងអើយជួយទិញអាឪឡឹតខ្ញុំអ្នកមីងអុំពូកទិញយកនឹងមួយថាសអស់នឹងបានរត់មកទៀតហើយ។
កះ អរ ម៉ែនឹងបានពុះអោយ?
ខះ ចាំ!
កះ ចាំ
ហើយអោយម៉ែនឹងបានបែងចែកលយុនឹងទិញបានប៉ុន្មានហើយលក់វិញនឹងបានប៉ុន្មានការនឹង?ដូ
ខះ ចាំចំណេញនឹង។
កះ
ដូចជាការជំនាន់មុននឹងម៉ាកយាយមានការទទួលកាងារនៅក្នុងជីវិតកូនទីពីនឹងម៉ាកយាយបានគ្រប់គ្រងក្រុមគ្រួសាររបស់ម៉ាកយាយអោយតែកូនច្បងនឹងមានភារកិច្ចគឺហាត់នឿងច្រើន?
ខះ
អូរខ្ញុំនឹងបានដើរស៊ីឈ្នួនដក់ស្ទូនហើយខ្ញុំនឹងបានពង់ដៃអស់ហើយហើយគេនឹងបានច្រង់ៗនឹងហើយខ្ញុំនឹងបានគេហៅខ្ញុំនឹងទៅស្ទូននឹងទៅហើយចង់បានលយុម៉ែឪនឹងក្រ។
កះ ការនឹងបានជួយសេដ្ឋកិច្ចនឹងបានធូរខ្លះដែរ?
ខះ
អើយបានធូរបើម៉ែខ្ញុំនឹងពិបាកចឹងនឹងម៉ែខ្ញុំនឹងគាត់ឥឡូវនឹងគាត់នឹងបានយ៉ាប់ណាស់គាត់នឹងបានចាស់ហើយ។
កះ ហើយចឹងអ្នកម្ដាយអ្នកមីងនឹងបាននៅរស់?
ខះ ម្ដាយខ្ញុំនៅរស់ទេហើយឪពុកខ្ញុំនឹងគាត់បានស្លាប់ហើយឪខ្ញុំនៅតែម្ដាយ។
កះ ចាំ!
ខះ គាត់នៅជាមួយនឹងកូនពៅនៅស្វាយរៀង។
កះ ចាំ
ចំពោះអ្នកមីងផ្ទាល់តើអ្នកមីងអើយនៅពេលនេះពួកគាត់បងប្អូនអ្នកមីងនឹងប្រាំពីរនាក់នឹងនៅណាអ្នកមីង?
ខះ នៅក្បែមគ្នានឹង។
កះ នៅស្វាយរៀងនឹង?
ខះ ចាំនៅខេត្តស្វាយរៀងនឹង។
កះ ប៉ុន្តែដូចជាមានតែម៉ាកយាយទេដែរបានមករស់នៅភ្នំពេញនឹង?
ខះ នៅបងខ្ញុំនឹងមួយដែរគាត់នឹងបាននៅស្ទឹ។
កះ នៅស្ទឹបន្តមកអ្នកមីងនឹងបាននៅភ្នំពេញ?
ខះ ចាំ!
កះ
ម៉ាកយាយនៅភ្នំពេញហើយបន្តមកមានប្អូននឹងប្រាំនាក់ទៀតដែររស់នៅស្រុកកំណើត?
ខះ ចាំ! រស់នៅស្រុកកំណើត។
កះ អូរនៅរៀងខ្លួនៗ?
ខះ ធ្វើសំណង់នឹងអ្នកមគ្រូអើយកម្មករសំណាង់។

កៈ ចុះបងប្អូននៅស្ដីនឹងនៅធ្វើអីគេ?
ខៈ
បងស្រីខ្ញុំនឹងគាត់នៅផ្ទះគាត់នៅចឹញ្ចឹមមាន់ទាចឹងបងប្រុសខ្ញុំនឹងគាត់អ្នករត់ម៉ូតូឌុប។
កៈ អរ!
ខៈ នៅបេនឡាននៅខេត្តកំពុងស្ពឺបងប្រុសខ្ញុំនឹង។
កៈ ចា៎!
ចឹងមានន័យថាពួកគេនឹងមានជីវភាពនឹងរៀងមធ្យមរបស់ពួកគេដែរមិនសូវជាអស្ចារ្យដែរគេនឹងអាចជួយខ្លួនគេនឹងបានគ្រាៗអីចឹងម៉ាកយាយ?
ខៈ ចា៎!
កៈ
ម៉ាកយាយអាចប្រាប់ខ្ញុំបានទេលោកឪពុកម៉ាកយាយគាត់ស្លាប់នៅអាយុនឹងប៉ុន្មានដែរ?
ខៈ
គាត់ស្លាប់នឹងតាំងពីកូនខ្ញុំទម្ងន់កូនខ្ញុំនឹងបានប្រាំពីខែឥឡូវកូនខ្ញុំនឹងដប់ប្រាំពីហើយ។
កៈ ចុះបើសិនជាអាយុគាត់នឹងប៉ុន្មានហើយម៉ាកយាយ?
ខៈ ខ្មោចឪឆ្នាំឆ្លូវឪនឹងគាត់អាយុប៉ុន្មានហើយ។
កៈឆ្លូវនឹងចិតកត់ហើយ ត្រូវជាប្ដីគាត់។
កៈ
ចិតសិបឆ្នាំហើយន៎េលោកតាចា៎ប៉ុន្តែគាត់ស្លាប់នឹងមិនមែនគាត់នឹងអាយុចិតកត់នឹងទេ?
ខ ៈតាំងពីកូនខ្ញុំនឹងអាយុប្រាំពីខែឥឡូវនឹងវាអាយុដប់ប្រាំពីហើយ។
កៈ ប្រហែលខ្ញុំបានគិតថាគាត់នឹងបានស្លាប់នឹងអាយុហារជាង?
ខៈ ប្រហែលគាត់នឹងបានស្លាប់នឹងអាយុហារជាង ហារមួយ
ហារពីនឹងគាត់នឹងបានស្លាប់។
កៈ ការនឹងគាត់នឹងបានស្លាប់នឹងដោយសារអីម៉ាកយាយ?
ខៈ គាត់នឹងខ្យល់គ។
កៈ អូរចា៎ ហើយគាត់នឹងមានឈ្មោះអីម៉ាកយាយ?
ខៈ គាត់ឈ្មោះហៀនសួន។
កៈ ហៀន សួន ចា៎ហើយចំអ្នកម្ដាយរបស់ម៉ាកយាយនឹងគាត់នឹងឈ្មោះអី?
ខៈ ចឹងម៉ែខ្ញុំនឹងឈ្មោះស្វាយហឹន។
កៈ ចឹងម៉ាកយាយមានបានចាំថាគាត់នឹងបានកើតនៅខេត្តណា?
ខៈ អត់បានចាំផងនឹងគ្រូ។
កៈ
ប៉ុន្តែដូចជាឆ្នាំខ្មែរអីចឹងប៉ុន្តែចាំទេចឹងអើយដូចអ្នកម្ដាយលោកឪពុករបស់ម៉ាកយាយគាត់ឈ្មោះហៀនសួនចា៎ គាត់នឹងបានកើតនៅឆ្នាំ១៩៨៦ចឹងណា?
ខៈ  ចា៎!
កៈ
ចឹងមានន័យថាស្រុកកំណើតគាត់នឹងគាត់ជាអ្នកនៅស្រុកស្វាយរលំនឹងខេត្តស្វាយរៀងនឹងជាមួយនឹងគ្នាហើយអ្នកម្ដាយរបស់ម៉ែយាយនឹងគាត់មានឈ្មោះថាស្វាយហ៊ុនគាត់កើតនៅឆ្នាំ១៩៨៨ចឹងមានន័យថាអ្នកម្ដាយរបស់ម៉ាកយាយគាត់អាយុបងឪពុក?
ខៈ ចា៎គាត់នឹងបានបងឪខ្ញុំ។
កៈ ចា៎! ហើយដូចគាត់នឹងជាអ្នកនៅស្វាយរៀងនឹងជាមួយនឹងគ្នាដែរ?
ខៈ ចា៎ នៅជាមួយនឹងគ្នាដែរ។
កៈ ចា៎ចឹងអើយម៉ាកយាយមានចាំថាគាត់នឹងបានកើតឆ្នាំខ្មែរដូចជាឆ្លូវ ខាល ថោះនឹងឆ្នាំអីគេដែលម៉ាកយាយ?
ខៈ ម៉ែខ្ញុំនឹងគាត់ឆ្នាំខាល។
កៈ ចា៎!
ខៈ តែឪខ្ញុំនឹងគាត់ឆ្នាំឆ្លូវ។

កៈ ចា៎
ដូចជាការនឹងជំនាន់នឹងនៅពីក្មេងណាម៉ាកយាយមានចាំថាឪអ្នកម្ដាយរបស់ម្ដាយនឹងគាត់មុនរបបអីចិញ្ចឹមម៉ាកយាយទេ?
ខៈ
គាត់ការពីនឹងខ្ញុំនឹងបានលឺម៉ែខ្ញុំគាត់នឹងបាននិយាយប្រាប់ខ្ញុំហើយខ្ញុំនឹងបានធំដឹងក្ដីមក។
កៈ ចា៎ !
ខៈ
ថាគាត់នឹងបានទៅស្វាយការជំនាន់នឹងយើងនឹងបានជិះកង់គាត់នឹងបានទិញក្រណាត់ទិញជាសារុងយកទៅលក់ទិញពីស្វាយយើងនឹងទៅក្បែងនឹង។
កៈ យកមកលក់នឹង?
ខៈ ចា៎ គាត់នឹងជិះកង់ការនឹងលក់ម៉ែខ្ញុំនឹងគាត់បានប្រាប់ខ្ញុំចឹងណា។
កៈ ចា៎ !
ខៈ ចា៎ គាត់នឹងយប់ណាគាត់នឹងបានដេកនៅនឹងចឹង។
កៈ ចា៎!
ខៈ ដល់គាត់នឹងបានទៅដល់ស្វាយស៊ីសុផនណាយកទៅលក់។
កៈចា៎!
ខៈ ចា៎!
កៈ
ចឹងមានន័យថាលោកឪពុកម៉ាកយាយដូចជាគាត់នឹងអ្នកមុខជំនួយនឹងតូចតាចមួយការនឹងគាត់នឹងបានដឹងកង់ទៅទិញសាច់ក្រណាត់យកមកលក់នៅស្រុកកំណើត?
ខៈ ចា៎យកមកលក់នៅស្រុកកំណើត។
កៈ នៅស្វាយស៊ីសុផនម៉ាកយាយ?
ខៈ នៅស្វាយស៊ីសុផន។
កៈ នៅជាយដែនថៃម៉ាកយាយ?
ខៈ គាត់នឹងបានទៅទិញដល់នឹង។
កៈ អូហ្អូតប៉ោយប៉ែតនឹងជិះប៉ុន្មានខែទៅដល់ម៉ាកយាយ?
ខៈ គាត់នឹងបានជិះកន្លះខែមើលទៅ។
កៈអូ!
ខៈ
គាត់នឹងបានធ្វើអរុតអីនឹងគាត់នឹងបានធ្វើល្អីអីនឹងជំនាន់នឹងគាត់នឹងបានប្រាប់ខ្ញុំ។
កៈ ចា៎!
ខៈ ការពីដើមមកនឹងគាត់នឹងបានធ្វើឆ្នាងអរុតធ្វើជាល្អីនឹងយកមកលក់។
កៈ ស្អកអីនឹងលក់?
ខៈ ចា៎!
កៈ ចា៎!
ខៈ យកមកលក់នៅឯងភ្នំពេញនឹង។
កៈ ចា៎ ប៉ុន្ដែការនឹងលក់នឹងអត់បានថ្លៃដូចឥឡូបនឹងទេ?
ខៈ មិនបានដូចឥឡូវនឹងការជំនាន់មុននឹង។
កៈ
ប៉ុន្ដែសំរាប់ម៉ាកយាយផ្ទាល់តើម៉ាកយាយនឹងបានគិតលោកឪពុកអ្នកម្ដាយដូចម្ដេចដែរថាគាត់នឹងជានមុស្សនឹងដែលណាគាត់នឹងបានស្លូតឬមួយគាត់នឹងកាច?
ខៈ ម៉ែខ្ញុំគាត់នឹងស្លូតចា៎។
កៈ ចា៎ ចំពោះលោកឪពុកនឹងរៀងកាច?
ខៈ
ឪពុកខ្ញុំនឹងក៏ស្លូតដែលដូចជាព្រះចឹងអត់ចេះមាត់ទេបើម៉ែខ្ញុំនឹងតរៀងគ្រាន់បើទិចបើឪពុកខ្ញុំនឹងអត់។
កៈ ចា៎!

ខ៖ ដឹងតែញ៉ាំញមអត់ចេះមាត់ទេគាត់នឹងស្លូតណាស់គាត់នឹងនោះ។
ក៖ ភាពជូរជត់កំសត់កំរងជាមួយនឹងគាត់នឹងមានខ្លះម៉ាកយាយមានទេ?
ខ៖ ចាំ មានច្រើនដែរ។
ក៖
តែដូចជាការនឹងម៉ាកយាយនឹងជួយចិញ្ចឹមម្ដាយហើយនឹងចិញ្ចឹមប្អូនអីនឹងដោយសារតែម៉ាកយាយនឹងទិទម្នាក់ទៅលើលោកឪពុកនឹងបានខ្លាំងណាស់ដែរ?
ខ៖ ចាំ!
ក៖ ចឹងមានន័យថា?
ខ៖ ចិញ្ចឹមប្អូនចិញ្ចឹមម្ដាយប្អូនខ្ញុំនឹងនៅតូចៗ។
ក៖ ចាំ
ចឹងមានន័យថាម៉ាកយាយនឹងដូចជាលោកឪពុករបស់ម៉ាកយាយអើយស្លាប់មុនម៉ាកយាយគាត់នឹងបានស្លាប់មុនម្ដាយម៉ាកយាយ?
ខ៖ ឪពុកខ្ញុំនែ។
ក៖ឪពុក!
ខ៖ ឪពុកខ្ញុំនឹងគាត់បានស្លាប់មុនហើយម្ដាយខ្ញុំនឹងគាត់បាននៅតើ។
ក៖ ចាំ គាត់នឹងបានស្លាប់ហើយម្ដាយនឹងនៅ?
ខ៖ គាត់នឹងបានស្លាប់ហើយម្ដាយខ្ញុំនឹងនៅ។
ក៖
រាល់ថ្ងៃនឹងអ្នកម្ដាយនឹងគាត់មានអាយុនឹងប៉ុន្មានហើយម៉ាកយាយអូតឡូវនឹងគាត់នឹងមានព្រះជុនណឹងប៉ែតជាងហើយ?
ខ៖  គាត់នឹងអាយុហារជាងហើយ។
ក៖ ចាំ គាត់នឹងនៅជាមួយនឹងប្អូន?
ខ៖ គាត់នឹងបាននៅជាមួយនឹងប្អូនពៅខ្ញុំ។
ក៖
ម៉ាកយាយមានធ្លាប់មានចាំសាច់រឿងអីខ្លះជាមួយនឹងពួកគាត់ពីក្មេងៗដែរទេ?
ខ៖ អស់ចាំផងនឹង។
ក៖
ការគាត់នឹងបានជួបគ្នានឹងជាប្ដីប្រពន្ធហើយជាមូលហេតុអីបានគាត់នឹងបានស្គាល់គ្នានឹងទល់គាត់នឹងទំនាក់ទំនងបានជាមានកូនចៅនឹងរាល់ថ្ងៃនឹងពីសាច់រឿងពួកគាត់នឹងខ្លះទេ?
ខ៖ ជំនាន់នឹងដូចគាត់នឹងតែខ្ញុំនឹងអត់បានចាំ។
ក៖ ចាំ!
ខ៖ អត់ចាំៗណាអូន។
ក៖
ចឹងម៉ាកយាយនឹងអត់ចាំលោកតាលោកយាយម៉ាកយាយគាត់នឹងមានឈ្មោះអ្វីខ្លះទេម៉ាកយាយនឹងមានកើតទាន់ទេ?
ខ៖ លោកតាខ្ញុំនែ៎។
ក៖ ចាំទាំងខាងអ្នកម្ដាយហើយនឹងលោកឪពុកណា?
ខ៖ តាខ្ញុំអើយហៀន ហាមហើយយាយខ្ញុំនឹងឈ្មោះអីយាយសយនៀក។
ក៖ អត់អីអ្នកមីងគ្រាប់តែប្រាប់ខ្ញុំឈ្មោះនឹងក៏បានដែរ?
ខ៖ ឈ្មោះនឹងឈ្មោះយាយសយ។
ក៖ ហើយដូចជាលោកយាយ?
ខ៖ លោកតាខ្ញុំនឹងហៀន ហាម។
ក៖ នឹងខាងលោកឪពុកហើយចុះខាងអ្នកម្ដាយ?
ខ៖ ខាងអ្នកម្ដាយខ្ញុំនឹងអើយតាសុមហើយនឹងយាយសុខ។
ក៖
តាសុមហើយនឹងយាយសុខហើយម៉ាកយាយនឹងបានកើតទាល់នឹងពួកគាត់ទេ?
ខ៖ ខ្ញុំនឹងទាន់យាយខ្ញុំនឹងទាន់។
ក៖ មានភាពតក់ក្ដៅជាមួយនឹងគាត់មានទេ?
ខ៖
ចាំទៅលេងហើយនឹងបានទៅមើលថែគាត់ការគាត់នឹងបាននៅឈឺរហើយនឹងគា

ត់នៅខ្វង់យាយខ្ញុំនឹងយាយសិខនឹងគាត់ខ្វង់គាត់នឹងបានសំរាមនៅនឹងកន្លែងនឹង។
ក៖ គាត់ឈឺរបានប៉ុន្មានហើយម៉ាកយាយដែរគាត់នឹងដើរអត់បានរួចនឹង?
ខ៖ គាត់ឈឺរប្រាំឆ្នាំកាលនឹងបានគាត់បានស្លាប់។
ក៖ អើចឹង!
ខ៖
ខ្ញុំនឹងបានធំដឹងក្តីហើយនឹងបានគាត់នឹងបានស្លាប់ហើយចឹងបានខ្ញុំចាំគាត់នឹងអាយុចិតជាងហើយ។
ក៖ ចឹងម៉ាកយាយនឹងបានជួបមើលគាត់នឹងទឹកក្តៅទឹកត្រជាក់?
ខ៖
ទឹកក្តៅហលយនឹងទឹកត្រជាក់ហើយកាលនឹងហើយខ្ញុំនឹងបានមិចទឹកអោយគាត់ទៀតកាលនឹង។
ក៖ ចាំហើយនឹងបានជួយមើលការខុសត្រូវគាត់?
ខ៖ បើតាខ្ញុំនឹងអត់ទាន់ទេ។
ក៖ គាត់នឹងបានទៅមុន?
ខ៖ ចាំនឹងហើយគាត់នឹងបានទៅមុនយាយ។
ក ៖
ម៉ាកយាយនឹងអាចដំណើរប្រាប់ជីវិតគាត់នឹងលោកតាអីនឹងអោយបានដឹងខ្លះទេ?
ខ៖ អត់ដែរដឹង។
ក៖ គាត់ដែរនឹងប្រាប់ទេ?
ខ៖ គាត់នឹងអត់ដែរប្រាប់អត់ដែរនឹងនិយាយ។
ក៖ ចឹងទាក់ទងនឹងក្រុមគ្រួសារទៀតណាម៉ាកយាយ?
ខ៖ ចាំ!
ក៖ គ្រួសារម៉ាកយាយនឹងទាំងអស់ជាអ្នករស់នៅស្វាយរៀង?
ខ៖ ចាំ!
ក៖ តាំងពីលោកតាតាំងពីលោកយាយមកម្លះ?
ខ៖ ចាំ!
ក៖
ចាំម៉ាកយាយនឹងមានសាច់ញាតិដ៏ទៃទៀរនៅក្រៅប្រទេសបើសិនជាប្រទេសថៃប្រទេសអាមេរិចប្រទេសកាណាដាមានទេ?
ខ៖ អត់មានផងនឹងគ្រូ។
ក៖
អត់មានទេសព្វថ្ងៃនេះមានក្មួយធ្វើការពលករនឹងទៅប្រទេសកូរ៉េនទេម៉ាកយាយ?
ខ៖ អត់មានផងហើយនឹងទៅថៃនឹងអតើមានដែរ។
ក៖ ហើយទាក់ទងនឹងខ្សែរជីវិត?
ខ៖ ធ្វើការសំណង់នៅភ្នំនឹងហើយនឹងនៅប្រវិត។
ក៖ ចាំ!
ខ៖ នឹងកូនក្មួយខ្ញុំនឹង។
ក៖ ចាំដូចជាទាក់ទង់នឹងខ្សែរជីវិតរបស់ម៉ាកយាយនឹងផ្ទាល់តែម្តងនឹងណា?
ខ៖ ចាំ!
ក៖ តើស្វាយមីរបស់ម៉ាកមុនយាយនឹងគាត់មានឈ្មោះអីដែរ?
ខ៖ គាត់នឹងឈ្មោះរុធធី។
ក៖ ហើយម៉ាកយាយនឹងបានរៀបការនឹងតាំងពីណាមក?
ខ៖
ហើយខ្ញុំនឹងបានរៀបការនឹងតាំងពីខ្ញុំនឹងបានដប់ប្រាំពីហើយឥឡូវនឹងខ្ញុំនឹងសែបសិនប្រាំបួនឆ្នាំ។
ក៖
ប៉ុន្តែការរៀនការនឹងជាមួយនឹងគាត់នឹងប៉ុន្តែប្រើជីវិតនឹងរស់នៅជាមួយនឹងគាត់នឹងបានប៉ុន្មានឆ្នាំ?

ខៈ ខ្ញុំនឹងបានកូនប្រាំចាំ។
កៈ កូននឹងប្រាំ?
ខៈ
ហើយកូនខ្ញុំនឹងបានប្រាំនឹងកូនខ្ញុំនឹងធំអស់ហើយហើយនឹងបានគាត់នឹងបាន
ស្លាប់នឹង។
កៈ គាត់នឹងបានស្លាប់នឹងដោយសារតែជំងឺ?
ខៈ ដុចខ្ញុំនឹងបានប្រាប់មិញចឹងណា។
កៈ
តើអាពិពាហ៍ពាហ៍របស់ម៉ាកយាយនឹងបានរៀបចំឡើងដោយអ្នកណាឬក៏រៀបចំ
ឡើងដោយឪពុកម្ដាយ ផ្ទាល់តែម្ដង?
ខៈ
ចាំរៀបចំដោយឪពុកម្ដាយខ្ញុំនឹងផ្ទាល់តែម្ដងតែម្ដាយខាងប្ដីខ្ញុំនឹងអត់បានមក
ទេហើយគាត់នឹងបានធ្វើការសំណាង់នឹងជានឹងខ្ញុំនឹងហើយម៉ែឪគាត់នឹងនៅ
ណោះហើយរៀបចំនឹងនៅផ្ទះនឹងហើយរៀបចំនឹងតែមួយព្រឹក។
កៈ ចាំ នឹងហើយ?
ខៈ ហើយមានមេក្រូហើយនឹងអាចារ្យអីនឹង។
កៈ មានន័យថាកានឹងបានសែន?
ខៈ ចាំ សែន។
កៈ សែននឹងបានមួយព្រឹក?
ខៈ ចាំ
កៈ
ហើយមួយនឹងបានហៅថាគ្រប់លណ្ដះដែលបានដឹងឡឺនឹងចាស់ទុំអីដែរចឹងណាមិ
នមែនជាការស្វាត់ៗអីដែរ?
ខៈ ចាំ!
កៈ
អ្វីដែរសំខាន់ជីវិតយើងនឹងជាអ្នកដែរបានទទួលនឹងខ្លួនធ្វើអ្វីមួយដែរស្វាត់ក៏វានឹ
ងអត់មានខ្វល់អោយតែយើងនឹងមានសុភមង្គលហើយការនឹងស្វាយមីរបស់អ្នក
មីងនឹងបានទទួលណងដៃអោយម៉ាកយាយនឹងបានប៉ុន្មានដែរ?
ខៈ ការនឹងបនលុយនឹងប៉ុន្មានម៉ឺនទេកាលនឹង។
កៈ បានប៉ុន្មានម៉ឺនកាលនឹង?
ខៈ បានលុយនឹងប្រាំម៉ឺន។
កៈ ដើម្បីនឹងអោយយើងនឹងបានទិញ?
ខៈ
ការនឹងគេនឹងបានចង់ដៃនឹងបានមួយនាក់នឹងបានទិចពួកម៉ាក់គាត់នឹងសំរា
ប់អ្នកដែរបានធ្វើសំណាង់នឹងដូចគ្នា។
កៈ ចាំ
ចឹងខ្ញុំនឹងមិនបាច់ចាំសួរថាម៉ាកយាយនឹងបានជួបគ្នាជីវិតជាប្ដីប្រពន្ធពីមុនជា
មួយនឹងគាត់នឹងជួបនៅកន្លែងណាដោយសារនៅន្លែងសំណាង់នឹង?
ខៈ ធ្វើការសំណាង់នឹងខេត្តស្វាយរៀងនឹង។
កៈ
នៅខេត្តស្វាយរៀងនឹងក្រោយមកម៉ាកយាយជីវិតមេម៉ាយនឹងអស់រយះពេលប្រាំពី
ឆ្នាំ?
ខៈ ចាំ!
កៈ ហើយនឹងបានទទួលជួបនឹងលោកតា?
ខៈ ចាំ ហើយនឹងបានជួបនឹងគាត់។
កៈ ហើយហេតុដូចជាលោកតានឹងគាត់មានឈ្មោះនឹងអ្វីដែរ?
ខៈ តាខ្ញុំនឹងឈឹមឈ្មោះឈឹមអី។
គៈ ខ្ញុំឈ្មោះឈឹម សុខ។
កៈ ឈឹមសុខចាំ ឬមួយក៏សឹុម?
ខៈ ឈឹមអ្នកគ្រួ។

កៈ
ឈឹមសុខចាំចឹងម៉ាកយាយនឹងបានរៀបការជាមួយនឹងម៉ាកយាយនឹងបានប៉ុន្មាននឆ្នាំម៉ាកយាយ?
ខៈ ចូលក្បាលប្រាំបួនឆ្នាំហើយ។
កៈ ចឹងជាមូលហេតុអីបានជាម៉ាកយាយនឹងបានស្គាលគាត់?
ខៈ
គេនាំគាត់នឹងទៅខ្ញុំនឹងរៀបកូនខ្ញុំមីងបងដោយសារចឹងទៅហើយកូនខ្ញុំនឹងនៅបន្ទប់ជាប់ខ្ញុំនឹងគាត់នាំគាត់នឹងទៅ។
កៈ គាត់នាំទៅ?
ខៈ
ចាំនាំទៅឃើញគាត់នឹងបាននាំគាត់ទៅហើយគាត់នឹងបានចេញចិត្តនឹងទៅដល់តែពេលគាត់នឹងបានចេញចិត្តចឹងទៅគាត់បាននាំកូនគាត់នឹងហើយអ្នកជិតខាងអោយទៅសួរហើយនឹងទៅដណ្តឹង។
កៈ
ចាំចឹងមានន័យថាម៉ាកយាយនឹងបានយល់ព្រមយកគាត់នឹងជាស្វាយមីដែរហើយប៉ុន្តែអត់មានអីជាចំណាង់អាពាហ៍ពាហ៍កូនចៅអីនឹងទេ?
ខៈ កូនចៅអៅនឹងអត់មានទេ។
កៈ
ប៉ុន្តែដោយលែងការរស់នៅជាមួយនឹងគាត់ជាមួយនឹងលោកតាគាត់មនុស្សស្លូតបូត?
ខៈ គាត់នឹងស្លូតហើយគាត់នឹងឆ្នាំខាលតើ។
កៈ
ឆ្នាំខាលនឹងតែគាត់នឹងស្លូតចឹងណាចាំចឹងអើយជាមួលហេតុដែលបានស្គាល់លោកតាគឺអ្នកជិតខាងនឹងជាអ្នកណែននាំអោយបានស្គាល់?
ខៈ ចាំ !
កៈ គាត់នឹងអត់បានអោយថ្លៃជំនួនទឹកដោះអីអោយម៉ាកយាយប៉ុន្មានខ្លះទេ?
ខៈ អត់
គាត់នឹងអតលក្រដែលនឹងអ្នកគ្រូគាត់នឹងបាននៅជាមួយនឹងកូនគាត់ហើយគាត់នៅផ្ទះនឹងជួយគេដែរនឹង។
កៈ ចាំ!
ខៈ គាត់នឹងដើរតែជួលផ្ទះកែដែលនឹងគាត់នឹង។
កៈ
ចឹងមានន័យថាម៉ាកយាយនឹងបានស្គាល់គាត់នឹងអត់មានទទួលជំនួនថ្លៃទឹកដោះអីទេប៉ុន្តែដោលលែងមាននិស្ស័យនឹងគ្នា?
ខៈ មាននិស្ស័យនឹងគ្នាជាមួយនឹងគ្នាទៅ។
កៈ ព្រមទទួលនឹងយកជាប្តីប្រពន្ធនឹងជាមួយនឹងគ្នាទៅ
ពីមុនមកម៉ាកយាយនឹងបានធ្លាប់បានរៀនភាសាខ្មែរនឹងបានខ្លះទេ?
ខៈ
បានតែថ្នាក់ទីពីនឹងជំនាន់នឹងបានក្រាលកន្ទេរៀនជំនាន់នឹងហើយដល់ពេលម៉ែឪនឹងពិបាកដូចថាម៉ែឪនឹងគាត់កាលនឹងពិបាកពេកម៉ែឪនឹងអោយរៀនតែខ្ញុំនឹងរៀនអត់ចូល។
កៈ ចាំ!
ខៈ ដឹងថាខ្ញុំនឹងចង់ទៅរកលុយ។
កៈ ចាំ!
ខៈ គេនឹងបានហៅទៅច្រូតណាទៅគេហៅទៅណាទៅស្ទូ
នណាក៏ទៅអោយតែបានលុយនឹងបានជួយម្តាយឪ។
កៈ ចាំ!
ខៈ រៀននឹងអត់ចូលរៀនកាលនឹងបានតែថ្នាក់ទីពី។
កៈ ដូចជាអី?
ខៈ កាលនឹងក្រាលកន្ទេនឹងរៀន។
កៈ ការពីនឹងជំនាន់លុននលពេលក្រាលកន្ទេរៀននឹងឬមួយជំនាន់អាពត?

ខៈ ជំនាន់នឹងអាពងតនឹងបានបែកហើយក៏អីទេ។
កៈ បែកហើយនឹង៧៩?
ខៈ ជំនាន់អាពតនឹងមើលទៅ។
កៈ ចា៎!
ខៈ ក្រាលកន្ទេនឹងអង្គុយរៀន។
កៈ
បើជំនាន់អាពតទេដែលបានក្រាលកន្ទេរៀននឹងណានៅជំនាន់លុននលនឹងអត់ស្ទូវបានរៀននឹងប៉ុន្មានទេដោយសារគេនឹងបានទុំលាក់គ្រប់នឹងផ្លោយប់ជំនាន់សម្តេចតានឹងគឺយើងនឹងបានសប្បាយចិត្តនឹងខ្លាំងតែម្តង?
ខៈ នឹងគ្រប់បែកផ្លោយនឹងខ្ញុំនៅក្នុងត្រង់សេទេ។
កៈ
ជំនាន់លុននលនឹងម៉ាកយាយក៏ដោយគឺម្តាយខ្ញុំនឹងក៏ដោយគឺអ្នកណាដែលបានកើតទាន់ជំនាន់នឹងលុននលនឹងគឺអត់ស្ទូវបានរៀនទេដោយសារចូលត្រង់សេនឹងរហូត?
ខៈ
ដូលត្រង់សេនឹងហើយវានឹងបានផ្លោយមកក្តាំមៗយើងនឹងបានចេញទៅចូលក្នុងត្រង់សេនឹងពួននៅក្នុងត្រង់សេនឹងហើយដាំបាយនឹងក៏នៅក្នុងត្រង់សេហើយដាំនឹងអត់អោយនឹងបានចេញផ្សែងមៗភ្លឺទៀត។
កៈ ចឹងដាំធ្វើមិចបានអត់អោយមានផ្សែងភ្លឺយកវានឹងទៅណា?
ខៈ
ធ្វើហើយយើងនឹងបានប្រហើរស្បូនឹងទិចទៅប្រហើរឡើងអោយវានឹងបានចេញទិចៗចឹងទៅណា។
កៈ អត់អោយចឹង?
ខៈ គាត់នឹងបានជិករណ្តៅននឹងអោយបានជ្រៅ។
កៈ ហើយមិនបានឆល្លួតចេញនឹងម៉ាកយាយ?
ខៈ ចា៎ ហើយគាត់នឹងបានយកស្បូនឹងមកគ្របពីលើកនឹង។
កៈ
ចា៎ចឹងសំរាប់ម៉ាកយាយតើម៉ាកយាយនឹងបានកើតទាន់ប៉ុន្មានជំនាន់ដែលសំរាប់ជីវិតម៉ាកយាយនឹង?
ខៈ កើតបានប៉ុន្មានជំនាន់ទេខ្ញុំនឹង។
កៈ ជំនាន់សម្តេចតាម៉ាកយាយនឹងបានកើតទាន់ទេ?
ខៈ ចា៎ទាន់កើតនឹងអត់ទាន់ផង។
កៈ
កើតនឹងអត់ទាន់ផងតែជំនាន់លុននលម៉ាកយាយនឹងបានកើតនឹងទាន់ដែលតែនៅតូច?
ខៈ នៅតូច!
កៈ នៅតូច?
ខៈ
ចា៎ជំនាន់អាពតនឹងខ្ញុំនឹងនៅតូចនៅពឹងនេះហើយខ្ញុំនឹងបានទៅបើបាយនឹងហូប។
កៈចា៎ជំនាន់នឹងគេអោយម៉ាកយាយនឹងបានកាបអាចរ៍គោទេកាលនឹង?
ខៈ កាបអាចរ៍គោ។
កៈ ហើយដូចជាដើរកាត់ក្រដៀងខែត?
ខៈ ចា៎ហើយកាត់ក្រដៀងខែត។
កៈ ហើយនឹងដូចជាអោយបានយៀមចំការពោតអីនឹង?
ខៈ អត់!
កៈ ហើយនឹងដោយសាជាគ្នាទីសំរាប់តែប្រុសទេកាលនឹង?
ខៈ យាយការនឹងខ្ញុំនៅតែក្នុងត្រង់សេនឹង។
កៈ ចា៎
នៅជំនាន់អាពតនឹងម៉ាកយាយនៅក្នុងត្រង់សេនឹងកើតដែលជំនាន់នឹង?

ខៈ
ចាំខ្ញុំនឹងបានរស់នៅជាមេយយនឹងឪហើយនឹងម្ដាយខ្ញុំហើយនឹងយាយខ្ញុំនឹងនៅជុំគ្នា។
កៈ ចាំមិនមែនបាននៅក្នុងត្រង់សេទេគឺបានរស់នៅផ្ទះនឹងជាមួយឪពុកម្ដាយ?
ខៈ ចាំ!
កៈ ហើយជំនាន់នឹងម៉ាកយាយគេនឹងអត់បានជំលៀងទៅណាទេ?
ខៈ ជំលៀងទៅដល់ត្របែកយើងនឹង។
កៈ ត្របែកយើងនឹង?
ខៈ បឹងត្របែក។
កៈ ពីស្វាយរៀងហើយមកដល់បឹងត្របែកយើងនឹង?
ខៈ ហើយជំនាន់ទៅណាទេកាលនឹងទៅឆ្ងាយណាស់អត់ស្គាល់។
កៈ
ដោយសារយើងនឹងបានចេះតែទៅនឹងតាមគេប្រើរយៈពេលនឹងវែងដែលកាលនឹង?
ខៈ ចាំ
វានឹងយូរកាលនឹងបានមកស្រុកវិញទល់តែបានបែកកាលនឹងបានមកវិញ?
កៈ ចាំ!
សំរាប់ម៉ាកយាយផ្ទាល់តើម៉ាកយាយនឹងបានចេះភាសាបទេសទរក្រៅពីភាសាខ្មែរដូចជាចិនហើយវៀតណាមថៃអង់គ្លេស?
ខៈ អរ!អតចេះសោះ។
កៈ បារាំងអីនឹង?
ខៈ អត់ចេទេ។
កៈ
ហើយសូមប្រាប់អំពីខ្សែរជិវិតម៉ាកយាយនឹងតាំងពីតូចរហូតដល់ធំណាម៉ាកយាយ ចាំ
ម៉ាកយាយនឹងបានធ្លាប់រៀនសាលាត្រឹមថ្នាក់ទៅពីនឹងរៀននឹងបានត្រឹមក្រាលកន្ទេទេអត់ដឹងថាសាលានឹងមានឈ្មោះអីទេ?
ខៈ ចាំអត់ដឹងសាលានឹងឈ្មោះអីនឹងផង។
កៈ ចាំ ប៉ុន្តែសំរាប់ម៉ាកយាយធ្លាប់ស៊ីឈ្នួននឹងដក់ស្ទូនគេ?
ខៈ ពីមុនមកចាំ!
កៈ
ជិវិតក្នុងការដក់ស្ទូនគេវាមានជីវិតណាដែលប្រើកាងារដូចជាស៊ីឈ្នួនរកលយុនឹងទៅតើម៉ាកយាយមានបានធ្វើកាងារអីនឹងក្រៅពីកាងារនឹងទេ?
ខៈធ្វើសំណង់ទៀត។
កៈ ហើយចឹងរាល់ថ្ងៃនឹងបានបន្តធ្វើអីទៀត?
ខៈ ធ្វើនឹងខាងអនាម័យ។
កៈ ចាងអនាម័យទៀត?
ខៈ ចាំ
កៈ
ចឹងមានន័យថាម៉ាកយាយពីមុននឹងអ្នកធ្វើច្រូតស្រូវនឹងអោយគេហើយដូចជាក្រោយមកនឹងបានធ្វើសំណង់ក្រោយមកទៀតនឹងបានធ្វើអនាម័យដល់រាល់ថ្ងៃនឹងទៅ?
ខ ហើយខ្ញុំនឹងបានលាងចានហាងកុយទាវ។
កៈ អនាម័យនឹងនៅក្នុងភោជណីដ្ឋានឬមួយក៍ជាសណ្ឋាគារ?
ខៈ អត់ទេរោងចក្រ។
កៈ
អរចឹងម៉ាកយាយនឹងបានធ្វើការនឹងខាងផ្នែកអនានម័មនឹងខាងរោងចក្រទេនែ?
ខៈ ចាំ!

ក៖
ហើយចឹងបានប្រាក់ខែនឹងបានច្រើនដែរនឹងហើយជួនពេលខ្លះថែមម៉ោងនឹងក៍បានថែមម៉ោងនឹងគេដែរ?
ខ៖ អត់ទេគេនឹងបានថែមម៉ោងខ្ញុំនឹងបានសុំគរនឹងបានមកផ្ទះចេញមកមុន។
ក៖ ដោយសារម៉ាកយាយនឹងជាបគ្គលិតចាស់បានសុំគេចេញចឹង?
ខ៖
ខ្ញុំនឹងបានទើបនឹងបានចូលដែរនឹងបានប៉ុន្មាននឹងហើយដោយសារខ្ញុំនឹងសារឈឺរបានខ្ញុំនឹងសុំគេនឹងបាចេញមកមុនចឹងហើយប្រាប់គេហើយខ្ញុំនឹងចុកត្រគៀបចំាដល់ពេលស្អែកនឹងខ្ញុំនឹងបានទៅពីប្រលឹមហើយខ្ញុំនឹងបានស្អាត់ទៀតចឹងទៅ។
ក៖ ចំា តាំងពីតូចមកដល់ធំនឹងអ្នកមីងនឹងមានការផ្លាក់ប្តូរអីដែលអ្នកមីង?
ខ៖ ចំាអត់ផងនឹងគ្រូ។
ក៖ ចឹងជីវិតនឹងនៅតែពិបាកដ៍ដែល?
ខ៖ នៅតែពិបាកនឹងដ៍ដែលអ្នកគ្រូអើយពិបាកនឹងទាន់តែបានស្លាប់មើលទៅ។
ក៖ អូអ្នកមីង?
ខ៖ ហើយបើតែពីនាក់យាយតាទាល់ទល់។
ក៖
អត់ទាន់ដឹងពេលវេលានឹងជាអ្នកប្រែប្រួលច្រើនហើយអត់កើតហើយសារតែសុខម៉ាកយាយត្រូវឆ្នោតអីហាសិបលានរៀលអីនឹង?
ខ៖ អត់មានអីទេអ្នកគ្រូផ្ទះក៍អត់ហើយដីនឹងក៍អត់។
ក៖ ចឹងអើយតាំងពីតូចមកដល់សព្វថ្ងៃនឹងចិត្តញ៉ាំម្ហូបអីជាងគេដែរ?
ខ៖ ចំា ខ្ញុំនឹងចូលចិត្តប្រហុក។
ក៖ ចូលចិត្តប្រហុក?
ខ៖ ហើយសម្លរម្ជូរហើយនឹងសម្លរប្រហើរសម្លរមស្ស៊ៅ។
ក៖ លោកតាធុញហើយប្រហុក?
ខ៖ មែនគ្រូហើយឃើញប្រហុកអើយខ្ញុំនឹងជប់ស្អុយប្រហុកណាស់។
ក៖
ចំាតើម៉ាកយាយតាំងពីតូចមកដល់សព្វថ្ងៃនឹងម៉ាកយាយនឹងបានធ្លាប់សប្បាយចិត្តជាមួយនឹងកម្មវិធីចូលឆ្នាំខ្មែរជារបែកប្រជាប្រិយបោះឈូង ទាញ់ព្រាត្រ័ខ្លះទេ?
ខ៖ អត់ដែរបានដើរទៅណាទេគ្រូអើយខ្ញុំនឹងនៅតែផ្ទះ។
ក៖ តាំងពីតូចមកដល់ឥឡូវនឹង?
ខ៖
ចំាឥឡូវនឹងរៀបចំទទួលទេវតាតិចតួចហើយគេនឹងបានហៅទៅវត្តនឹងបានមួយវត្តនឹងពីវត្តចឹងទៅ។
ក៖ ចុះពីក្មេងនឹងអត់បានធ្លាប់នឹងបានដើរលេងទៅវត្ត?
ខ៖
ពីក្មេងនឹងខ្ញុំនឹងបានឧស្សារដើរលេងទៅវត្តមួយនឹងពីវត្តដូចថាវត្តនឹងនៅស្រុកណា។
ក៖ ចំា វត្ត!
ខ៖ ទៅវត្តស្វាយច្រាំហើយនឹងបានទៅលេងចឹងទៅ។
ក៖ ចំា! បុណ្យទាននឹងបានសប្បាយ?
ខ៖ ចំា!
ក៖ មួយរដូវៗ?
ខ៖ ចំា ចាស់ពីដើមសប្បាយណាស់។
ក៖ ម៉ាកយាយចេះច្រៀងទេ?
ខ៖ ចំា!
ក៖ ម៉ាកយាយនឹងបានចេះច្រៀងទេ?
ខ៖ អត់ចេះទេ អូរអ្នកគ្រូហើយខ្ញុំនឹងមិនបានចេះទេ។
ក៖ អត់ចេះរាំនឹងមិចនេងបានសប្បាយ?

ខ៖
បើវាំនឹងខ្ញុំនឹងបានចេះតែតិចតួចហើយបើអោយខ្ញមនឹងច្រៀងនឹងខ្ញុំនឹងអត់បានចេះច្រៀងទេ។
ក៖ ចា៎!
ចឹងនៅក្នុងក្រុមគ្រួសាររបស់ម៉ាកយាយកូនម៉ាកយាយឬមួយចៅរបស់ម៉ាកយាយមានអ្នកណាដែលបានលេងឧបករណ៍ដូចជាជីតា
ចាប៉ីហើយមានខាងផ្នែកសិល្បៈមានទេ?
ខ៖ អត់មានអ្នកណាចេះទេគ្រូអើយ។
ក៖ ប៉ុន្តែម៉ាកយាយមានកុំណើតអោយបានចេះក្នុងផ្នែកនឹងទេ?
ខ៖ កូនខ្ញុំ។
ក៖ កូនចៅជំនាន់ក្រោយ?
ខ៖ កូនចៅនឹងអោយវានឹងបានចេះតែអោយវានឹងបានខំរៀន។
ក ដោយសារយើងនឹង?
ខ៖ ដោយសារយើងនឹងអត់លុយ។
ក៖ ដោយសារយើងនឹងអ្នកមានសេដ្ឋិកិច្ចអូចឹងណា?
ខ៖ ចា៎!
ក៖ ចឹងម៉ាកយាយនឹងបានអោយគាត់នឹងបានចូលដែរ?
ខ៖ ចា៎
ក៖ ផ្ទះម៉ាកយាយនឹងបានរស់នៅជាមួយនឹងឪពុកម្ដាយផ្ទះមិនដែរម៉ាកយាយ?
ខ៖ ផ្ទះនឹងតូចម៉ងអ្នកគ្រូ។
ក៖ លណ្ដះនឹងមិចដែរដូចជាដំបូងនឹងបានធ្វើអំពីអី?
ខ៖ ដំបូងនឹងបាំងស្លឹកយើងកាលនឹងដេរស្លឹក។
ក៖ ចា៎
ខ៖ ហើយយកមកបាំងណា។
ក៖ ជញ្ជាំងនឹងស្លឹកដែរ?
ខ៖ ចា៎
ក៖ ហើយរនៀបនឹងយើងធ្វើអំពីអីដែល?
ខ៖ រនៀបនឹងដើមស្បីយើងនឹង។
ក៖ នឹងពីជំនាន់ដែរម៉ាកយាយនឹងបានរស់នៅជាមួយនឹងឪពុកម្ដាយនឹង?
ខ៖ ចា៎ ឪពុកម្ដាយនឹងចា៎ៗ
ក៖ ហើយដូចជារាល់ថ្ងៃនឹងមានការផ្លាក់ប្ដូរផ្ទះនឹងទេ?
ខ៖ នៅរាល់ថ្ងៃនឹងនៅដ៏ដែរនឹងគ្រូអើយ។
ក៖ នៅដ៏ដែរនឹង?
ខ៖ នៅដ៏ដែរ។
ក៖ ចា៎!
ខ៖ ចា៎វានឹងបានរៀនជំតិច។
ក៖ អូចឹងបានកែច្នៃតិចតួចដែរនឹង?
ខ៖
គាត់នឹងក៏មេម៉ាយដែលអ្នកគ្រូអើយគ្នានឹងបានធ្វើការសំណង់ចិញ្ចឹមម្ដាយផងហើយនឹងចិញ្ចឹមកូនផងគ្នានឹងហើយដឹងគ្នានឹងមេម៉ាយកូនប៉ុះន្នានមេម៉យានឹងកូនពីរ។
ក៖ ចា៎! ហើយស្វាយមីគាត់នឹងទៅណាហើយ?
ខ៖ លែងគ្នា។
ក៖ អូលោកយាយ ចឹងអើយតើ?
ខ៖
គ្នានឹងតស៊ូរណាស់គ្នានឹងចិញ្ចឹមម្ដាយនឹងហើយមិនដែលនឹងបានស្គាល់នៅផ្ទះនឹងមិចហើយនឹងបានធ្វើសំណង់នៅពេញនឹង។
ក៖
ផ្ទះដែលម៉ាកយាយបានរស់នៅជាមួយនឹងឪពុកម្ដាយតាំងពីតូចរហូតមកដល់ធំនឹងដូចជាគាត់នឹងបានធ្វើខ្លួនឯងឬក៏គាត់នឹងបានជួយគេនឹងធ្វើ?

ខ៖
ខ្មោចឪខ្ញុំនឹងគាត់ជាងហើយនឹងប្អូនគាត់នឹងជាអ្នកជាងដែរហើយនឹងបានមកជួយធ្វើគាត់នឹងទៅ។
ក៖ ចា៎ ដល់ពេលជួយធ្វើចឹងទៅ?
ខ៖ ចា៎
ហើយនៅដាំបាយអីនឹងអោយហូបហើយនឹងបានអោយលុយគាត់នឹងបានតិចតួចនឹង។
ក៖ ការនឹងបានមានសំភារះកាលនឹងមានម៉ូទ័រកាត់នឹងតើកាលនឹងទេ?
ខ៖ អូការនឹងអត់ទាន់មានចឹងទៅមានតែពូថៅ ហើយនឹងអាណារ។
ក៖ ហើយនឹងមានណារចឹងជំនាន់នឹងអត់មានម៉ារទ័រទេនេ៎?
ខ៖ ចា៎អតទាន់មានទេ។
ក៖
ចឹងតើទាក់ទងនឹងបញ្ហាម៉ាកយាយដែរបានរៀនចំនាញពីឪពុកម្តាយដូចជាកាកូស្តុរត្នាត សិក្សកម្មដំត្បាញហើយនឹងខាងធ្វើជាតុទូអំពីផ្តៅ
ឬមួយក៏វិញខ្សែរព្ទលចឹងអីណាហើយម៉ាយាយនឹងបានធ្វើជាក្រមាអីនឹងតើម៉ាកយាយនឹងចេះទេ?
ខ៖អត់ចេះទេខ្ញុំនឹងអត់ដែរនឹងបានរៀនផងនឹងចា៎។
ក៖ ជំនាញដែរម៉ាកយាយនឹងបានចេះពីក្រុមគ្រួសារគឺធ្វើស្រែនឹងតែម្តង?
ខ៖ ធ្វើស្រែ។
ក៖
ដោយសារតែម៉ាកយាយនឹងបានប្រើជាជិវិតជាអ្នកកូនស្រែចំការចឹងបានចេះធ្វើចឹងចេះធ្វើស្រែនឹងតែម្តង?
ខ៖ ចេះធ្វើស្រែ។
ក៖
មានបញ្ហាណានៅក្នុងជីវិតដែរមិនអាចបំភ្លេចបានហើយនឹងធ្លាប់ឆ្លងកាត់មក?
ខ៖ អឺ
ភ្លេចហើយអ្នកគ្រូអើយប្រវិត្តពីមុនមកនឹងធ្លាប់ពិបាកវេនាហើយឥឡូវនឹងក៏នៅពិបាក។
ក៖ ចា៎
មានគ្រាណាដែរម៉ាកយាយបានចាំមួយចំនួយតូចអំពីតសូវជូរជត់ខ្លាងបំផុតមានទេម៉ាកយាយ?
ខ៖ ចា៎មាន។
ក៖ តើម៉ាកយាយអាចប្រាប់ខ្ញុំបន្តិចបានទេ?
ខ៖ ការនឹងខ្ញុំនឹងបានបង្អែមហើយខ្ញុំនឹងបានទូរដើរលក់តាមផ្ទះអើយ
ថាការនឹងបានផុតរដូវស្ទូនហើយចឹងទៅខ្ញុំនឹងបានធ្វើបង្អែមហើយខ្ញុំនឹងបានធ្វើដូចជាបាញ់ នឿកហើយនឹងធ្វើបាញ់ប៉ែវ។
ក៖ បាញ់ប៉ែវ?
ខ៖
ចា៎ហើយនឹងកូរលបទូរដើរលក់តាមផ្ទះនឹងដូរយកអង្ករមួយនឹងហើយយកមកហើយអ្នកណាមានអង្ករយើងនឹងយកអង្ករទៅហើយអ្នកណាគេមានលយុយើងនឹងដូរយកលុយទៅ។
ក៖ អូរដើរដូរគ្រប់ដំបន់ចឹងទៅ?
ខ៖ចា៎ដើរតាមភូមិគ្រាប់ផ្ទះនឹង។
ក៖
ចា៎ចឹងកាលជំនាន់នឹងម៉ាក់យាយកំសត់ជាងគេគឺជំនាន់លក់បង្អែមនឹងម៉ង?
ខ៖ ចា៎កាលជំនាន់លក់បង្អែមនឹងចា៎ដើរទូរលក់តាមផ្ទះនឹង។
ក៖ ចា៎អត់មានពេលណាដែលសប្បាយចិត្តទេ?
ខ៖ អត់មានទេដឹងថាព្រលឹមឡើងចេញទៅបាត់ទៅ។
ក៖ ព្រលឹមឡើងអររាល់ថ្ងៃនឹងក៏អត់មានដែរ?
ខ៖ ចា៎!រាល់ថ្ងៃក៏អត់ដែលកូនអើយ។

ក៖
ចាំដូចជាមូលហេតុអ្វីដែលម៉ាក់យាយដោយសារអត់នៅក្នុងចំណុតណាដែលម៉ាក់យាយរាល់ថ្ងៃនឹងម៉ាក់យាយនៅតែទទួលនូវជីវិត្តដែលមិនសប្បាយចិត្តទៀតតើមានបញ្ហាណាខ្លះទៅម៉ាក់យាយ?
ខ៖
ពិបាកនៅតែពិបាកចឹងគ្រាន់តែយើងអត់ទាន់មានផ្ទះសំបែងនៅហើយយើងនៅជួរផ្ទះគេរហូតនឹងដោយប្ដីខ្ញុំគាត់ចាស់ហើយមិនដឹងទៅរកអីអោយបានទិញផ្ទះទិញអីនៅចឹងណាស់។
ក៖ ចាំហើយពិបាកចិត្ត?
ខ៖ ចាំពិបាកចិត្ត។
ក៖
ចាំហើយចុះនៅក្នុងមួយជីវិត្តរបស់ម៉ាក់យាយតើម៉ាក់យាយមានគោបំណងចង់ធ្វើអ្វីខ្លះនៅក្នុងជីវិត្តរបស់ម៉ាក់យាយ?
ខ៖ ខ្ញុំចង់អោយមានអោយបានតែមិនដឹងថាធ្វើមិនអោយមានអោយបាន។
ក៖ ចាំតែគោរបំណងគ្រាន់តែចង់បានផ្ទះផ្ទាល់ខ្លួន?
ខ៖
ចាំចង់បានផ្ទះផ្ទាល់ខ្លួននៅមួយក៏បានដែរមួយគ្រែពីរគ្រែពីនាក់យាយតាក៏បានដែរ។
ក៖ ចាំនេះគឺជាគោរបំណងរបស់ម៉ាក់យាយណាស់?
ខ៖ ចាំ!
ក៖ អត់មានអ្វីផ្សេងទៀតទេ?
ខ៖ អស់ហើយអត់មានពាក្រអីនិយាយទេ។
ក៖ ចាំចឹងម៉ាក់យាយអស់មានពាក្រអ្វីនិយាយហើយ?
ខ៖ ចាំ!ចឹងបានតារដី៣ ៤
ម៉ែត្រនៅក៏បានដែលបានតារមួយគ្រែនៅតារពីរនាក់យាយតានឹងក៏បានដែរហើយយើងចេះតែរកទក់ៗទៅ។
ក៖ ចាំដើម្បីចិញ្ចឹមជីវិត្ត?
ខ៖ ចាំដើម្បីចិញ្ចឹមជីវិត្តយើងជួរផ្ទះគេមួយខែៗនឹងអោយតារគេកូនអើយ។
ក៖ ចាំគឺជាប្រាក់ខែយើងបើកមកអោយគេ?
ខ៖ ចាំបើកមកអោយគេយើងមិនអាចជំពាក់គេបានទេលុយទឹកលុយភ្លើង។
ក៖
ចាំត្រូវហើយចឹងជាចុងក្រោយតើម៉ាក់យាយមានពាក្យអ្វីចង់ផ្ដៅផ្ញើទៅកូនចៅជំនាន់ក្រោយអោយគាត់ខំប្រឹងរៀនសូត្របូមួយអោយពួកគាត់ធ្វើការងារអ្វីអោយជាក់លាក់កុំអោយពិបាកដូចជីវិត្តរបស់ម៉ាក់យាយលោកតាអីចឹងណាស់?
ខ៖ ចាំ!
ក៖ ចាំចឹងតើម៉ាក់យាយមានអ្វីដែលផ្ដៅផ្ញើទេ?
ខ៖
ចាំ!ខ្ញុំសូមផ្ដៅផ្ញើទៅអោយកូនចៅក្រោយអោយពួកវាខំប្រឹងរៀនកុំអោយដើរលេងអោយជៀសអោយផុតពីគ្រឿងញៀញគ្រឿងអីព្រោះសង្គមគេស្អប់ខ្ពើមអោយជៀសអោយផុតអោយខិតខំប្រឹងរៀនសូត្រកុំអោយម្ដាយចាំអោយខំប្រឹងរៀនដើម្បីបានធ្វើការងារធំ។
ក៖ ចាំៗចឹងម៉ាក់យាយមានតារពិននឹងទេណាស់?
ខ៖ ចាំ!ៗៗ
ក៖
ចាំចឹងជាចុងក្រោយខ្ញុំសូមអរគុណម៉ាក់យាយដែលបានចំណាយពេលវេលាដ៏មានតម្លៃសំរាប់រូបខ្ញុំនឹងមកកាន់សាលារៀន B Y U
របស់ពួកខ្ញុំទាំងអស់គ្នាហើយជាពិសេសសូមអោយអាកាសចូលឆ្នាំថ្មីសូមអោយម៉ាក់យាយរកស៊ីមានបានសូមជួបតែពុទ្ធធម៌ព្រះសង្ឃហើយសូមអោយក្រុមគ្រួសាររបស់លោកយាយមានក្ដីសុខទាំងអស់គ្នាហើយសង្ឃឹមថាកូនចៅនឹងបានស្ដាប់អំពីជីវប្រវត្តរបស់ម៉ាក់យាយផងដែលចាំខ្ញុំសូមអរគុណម៉ាក់យាយ។